# វេទិកាសហគមន៍អ្នកប្រតិបត្តិឧបករណ៍មិនបង្កទំនាស់ ក្រោមប្រធានបទ "របៀបនៃការបញ្ចូលគ្នារវាងទស្សនទានឧបករណ៍មិនបង្កទំនាស់ នៅក្នុងការអនុវត្តកម្មវិធី/គម្រោង "

**កាលបរិច្ឆេទ៖ ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៥ (ចាប់ពីម៉ោង៨ព្រឹក ដល់៤:៣០នាទីរសៀល)**

**ទីកន្លែង៖ រាជធានីភ្នំពេញ (ទីតាំងជាក់លាក់នឹងបញ្ជាក់ជូនពេលក្រោយ)**

## ១.សាវតា

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) គឺជាអង្គការសមាជិកភាពឈានមុខគេជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសនៅក្នុងប្រទេសកម្ពុជា។ គ.ស.ក បានបង្កើត និងអនុវត្តកម្មវិធីគ្រប់គ្រងអភិបាលកិច្ច (GHP) ២០២៤-២០២៨ ដើម្បីរួមចំណែកលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ បង្កើតបរិយាកាសអំណោយផលល្អសម្រាប់អង្គការសង្គមស៊ីវិល និងដោះស្រាយបញ្ហាប្រឈមក្នុងការអភិវឌ្ឍន៍នៅកម្ពុជា។

តាមរយៈវិធីសាស្ត្រការងាររបស់ខ្លួន គ.ស.កនឹងលើកទឹកចិត្តដល់ការរួមបញ្ចូលឧបករណ៍មិនបង្កទំនាស់ (Do No Harm- DNH) និងវិធីសាស្ត្រផ្អែកលើសិទ្ធិ (RBA) ទៅក្នុងអង្គការ និងសកម្មភាពរបស់ដៃគូ និងសមាជិករបស់ខ្លួន។ វិធីសាស្ត្រនេះ សង្កត់ធ្ងន់ទៅលើការកាត់បន្ថយឲ្យបានអប្បបរមានូវផលវិបាកជាអវិជ្ជមានដែលមិនបានរំពឹងទុក និងការបង្កើនផលជះជាវិជ្ជមាននៅក្នុងសកម្មភាពនៃកម្មវិធី ឬគម្រោង។ សកម្មភាពជាបន្តបន្ទាប់ត្រូវបានបង្កើតឡើង និងលើកកម្ពស់ចំណេះដឹង និងសមត្ថភាពសម្រាប់អង្គការសង្គមស៊ីវិលទៅលើ DNH ដែលរួមមាន សិក្ខាសាលាផ្សព្វផ្សាយ សិក្ខាសាលាស្តីពីការអនុវត្ត ការបង្វឹកការរៀន និងការចែករំលែកការអនុវត្តតាមរយៈវេទិកាសហគមន៍នៃអ្នកប្រតិបត្តិជាដើម។

ដូច្នេះ វេទិកាអនុវត្តសហគមន៍មិនបង្កទំនាស់ (DNH) គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពផ្សេងទៀត ដែលរៀបចំពីរដងក្នុងមួយឆ្នាំ ដើម្បីផ្តល់ឱកាសសម្រាប់ការចែករំលែកបទពិសោធន៍ កសាងបណ្តាញ ការកែលម្អជាបន្តបន្ទាប់ និងការច្នៃប្រឌិតក្នុងចំណោមអ្នកអនុវត្ត DNH ។ វេទិកាសហគមន៍នៃអ្នកប្រតិបត្តិ លើកទី១នៅឆ្នាំ២០២៥នេះ នឹងគ្រោងរៀបចំឡើងនៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៥ ហើយរំពឹងថានឹងមានអ្នកចូលរួមចំនួន ៤០ នាក់ ដើម្បីមានឱកាសជួបជុំគ្នា និងចែករំលែកបទពិសោធន៍ ការសិក្សារៀនសូត្រជាដើម។



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

## ២.គោលបំណង

- ដើម្បីចែករំលែកចំណេះដឹង បទពិសោធន៍ក្នុងដំណើរការអនុវត្ត Do No Harm នៅក្នុងកម្មវិធី/គម្រោង ក្នុងចំណោមស្ថាប័ននិងអ្នកអនុវត្ត។
- ដើម្បីឆ្លុះបញ្ចាំង និងរៀបចំផែនការរៀនសូត្រពេលខាងមុខបន្តទៀត។

## ៣.សមាសភាពអ្នកចូលរួម

- តំណាងបុគ្គលិក ០២ នាក់ក្នុងមួយស្ថាប័ន ចំពោះស្ថាប័នដែលធ្លាប់បានចូលរួមសិក្ខាសាលាDNH យ៉ាងតិច០១វគ្គ (DNH exposure workshop)
- បុគ្គលដែលបានចូលរួមក្នុងសិក្ខាសាលាផ្សព្វផ្សាយ DNH និងអនុវត្តគោលគំនិត/ប្រើប្រាស់ឧបករណ៍
- សមាជិកនៃក្រុម Do No Harm Cambodia (DNHC) ។

## ៤.ការរៀបចំ និងឥស្សូរការ

- ការចូលរួមវេទិកានេះ គឺមិនគិតថ្លៃទេ
- អាហារថ្ងៃត្រង់ អាហារសម្រន់ និងសម្ភារៈនឹងត្រូវបាន ផ្តល់ជូនដោយអង្គការ គ.ស.ក
- ថ្លៃធ្វើដំណើរ ការស្នាក់នៅ និងកន្លែងស្នាក់នៅ នឹងត្រូវរ៉ាប់រងដោយអង្គការសាមីរបស់អ្នកចូលរួម
- សូមចុះឈ្មោះតាមរយៈតំណភ្ជាប់ និងយ៉ាងយូរត្រឹមម៉ោង៥:០០ល្ងាច ថ្ងៃទី០៨ ខែសីហា ឆ្នាំ ២០២៥។
- តំណភ្ជាប់ចុះឈ្មោះចូលរួម៖ https://forms.office.com/r/DTQJzfzCPa

បញ្ជីចុះឈ្មោះអ្នកចូល
រួម វេទិកាសហគមន៍អ្នកប្រតិបត្តិ
ឧបករណ៍មិនបង្កទំនាស់

## ៥.សេចក្តីព្រាងកម្មវិធី

| ពេលវេលា | សកម្មភាព | អ្នកសម្របសម្រួល/វាគ្មិន |
|---|---|---|
| ៨:០០-៨:៣០ | ការអញ្ជើញមកដល់ និងចុះឈ្មោះ | ក្រុមការងារ គសក (CCC) |
| ៨:៣០-៨:៥០ | មតិស្វាគមន៍ និងណែនាំអំពីកម្មវិធី | **តំណាងពីអង្គការ CCC**<br>(នឹងបញ្ជាក់ជូនពេលក្រោយ) |
| ៨:៥០-១០:០០ | **វគ្គទី១៖ រំលឹកអំពីជំហ៊ាន និងគោលការណ៍នៃឧបករណ៍មិនបង្កទំនាស់**<br>• ជំហ៊ាន និងគោលការណ៍DNH និងការបញ្ជ្រាបនៅក្នុងការអនុវត្តគម្រោង/កម្មវិធី | **លោក ឈិត មុន្នី**<br>សមាជិកក្រុមការងារបច្ចេកទេសនៃឧបករណ៍មិនបង្កទំនាស់ (DNHC-T) |
| ១០:០០-១០:១៥ | *សម្រាក និងពិសារអាហារសម្រន់ពេលព្រឹក* | តំណាងអង្គការគ.ស.ក |



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability គណនេយ្យភាព
GPP
23/02/2023 22/02/2028
Symbol of Trust

| | | |
|---|---|---|
| ១០:១៥-១២:០០ | **វគ្គទី២៖ ការចែករំលែកបទពិសោធន៍ការអនុវត្តឧបករណ៍មិនបង្កទំនាស់**<br><br>**សំណួរឆ្លុះបញ្ចាំង៖**<br>• តើអ្នកបានយកទស្សនាទាន/ឧបករណ៍មិនបង្កទំនាស់ទៅប្រើប្រាស់ក្នុងការអនុវត្តគម្រោង/កម្មវិធីដោយរបៀបណា?<br>• តើអ្វីជាការផ្លាស់ប្តូរ/ប្រែប្រួល?<br>• តើអ្នកបានជួបបញ្ហាប្រឈមអ្វីខ្លះក្នុងដំណើរការប្រើប្រាស់/អនុវត្ត?<br>• តើអ្វីជាមេរៀនដែលអ្នកចង់ចែករំលែក/រៀនសូត្របាន? | ចែករំលែកដោយ៖<br>▪ តំណាងពីម្ចាស់ជំនួយ<br>▪ តំណាងអង្គការសង្គមស៊ីវិល<br>▪ តំណាងពីអាជ្ញាធរមូលដ្ឋាន<br>▪ តំណាងពីសហគមន៍<br><br>**សម្របសម្រួលកិច្ចពិភាក្សា៖ អ្នកស្រី ភួន កែវគង្គា សមាជិកក្រុមការងារបច្ចេកទេសឧបករណ៍មិនបង្កទំនាស់** |
| ១២:០០-០១:៣០ | *សម្រាកពិសារអាហារថ្ងៃត្រង់* | ក្រុមការងារ គសក (CCC) |
| ០១:៣០-០៣:០០ | **វគ្គទី៣៖ កិច្ចពិភាក្សាអំពីការប្រែប្រួលបរិបទ និងការប្រើប្រាស់ឧបករណ៍មិនបង្កទំនាស់**<br>• ការប្រើប្រាស់ឧបករណ៍មិនបង្កទំនាស់ នៅក្នុងស្ថានភាពជំនួយថវិកា កាន់តែថយចុះ<br>• ការប្រើប្រាស់DNH ប្រកបដោយប្រសិទ្ធិភាពនៅក្នុងការអនុវត្តគម្រោង/កម្មវិធី | **លោក ឡាវ ប៊ុនរិទ្ធី**<br>សមាជិកក្រុមការងារបច្ចេកទេសនៃឧបករណ៍មិនបង្កទំនាស់ (DNHC-T) |
| ០៣:០០-០៣:១៥ | សម្រាក | ទាំងអស់គ្នា |
| ០៣:១៥-០៤:១៥ | **វគ្គទី៤៖ ការឆ្លុះបញ្ចាំង និងការប្រើប្រាស់ឧបករណ៍DNH នៅក្នុងគម្រោង/កម្មវិធី**<br><br>• តើអ្នកបានយកវាទៅអនុវត្តដែរទេ?<br>• តើអ្វីជាការប្រឈម និងមេរៀនក្នុងការអនុវត្តគោលគំនិតនោះ?<br>• ហេតុអ្វីត្រូវគិតអំពីឧបករណ៍មិនបង្កទំនាស់នៅក្នុងការអនុវត្តគម្រោង/កម្មវិធី? | **លោក លឹម ផៃ ឬ**<br>**លោក ឡាវ ប៊ុនរិទ្ធី**<br>សមាជិកក្រុមការងារបច្ចេកទេសនៃឧបករណ៍មិនបង្កទំនាស់ (DNHC-T) |
| ៤:១៥-៤:៣០ | វាយតម្លៃកម្មវិធី<br>មតិបូកសរុប និងបិទកម្មវិធី | តំណាងក្រុមការងារបច្ចេកទេសនៃឧបករណ៍មិនបង្កទំនាស់ (DNHC-T) |

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង:**
អ្នកស្រី ភោគ ស្រីពេជ្រ (អ្នកឯកទេសពង្រឹងបណ្តាញ)
លេខទំនាក់ទំនង៖ ០៨៩ ៨១ ៨១ ៧៦
សារអេឡិចត្រូនិច៖ sreypich.phok@ccc-cambodia.org

**កំណត់សម្គាល់៖** CCC រក្សាសិទ្ធិក្នុងការផ្លាស់ប្តូររបៀបវារៈ អាស្រ័យលើឧបសគ្គពេលវេលា និងភាពអាចរកបាននៃវាគ្មិន។ CCC នឹងបង្ហោះឯកសារ រូបថត និងសកម្មភាព និងគំនិតសំខាន់ៗ នៅក្នុងគេហទំព័រ CCC និងប្រព័ន្ធផ្សព្វផ្សាយសង្គមសម្រាប់ការចូលប្រើជាសាធារណៈ។